ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌ
លេខ៖ ៣៩០ អ.ក
ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១
ជំនុំជម្រះលេខ៖ ១៥៣៤ ជ.រ
ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១
សាលក្រមលេខ: ៣៣ (ប)
ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកណ្ដាល
នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ ដោយមានសមាសភាព៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាប្រធានក្រុមប្រឹក្សា
លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

## ដើម្បីជំនុំជម្រះ

**លើសំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩០ អ.ក ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ដែលមាន៖**

១/-ជនជាប់ចោទឈ្មោះ [redacted] **ហ៉ាំងតឹង** ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិវៀតណាម មុខរបរលក់ដូរ ទីលំនៅកំណើតនៅ [redacted] ប្រទេសវៀតណាម និងទីកន្លែងមុនពេលឃាត់ខ្លួននៅផ្លូវលេខ២៨៨ សង្កាត់បឹងកេងកង ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] វឹងភឿង (រស់) ម្ដាយឈ្មោះ [redacted] ធីវ៉ាន់ (រស់) នៅលីវ ទោសពីមុនគ្មាន។

**(ឃាត់ខ្លួននៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ និងឃុំខ្លួនតាមដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ: ៧៩៨ ដក.សឃខ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល)។**

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ហ៉ាំងតឹង**។

២/-ជនជាប់ចោទឈ្មោះ [redacted] **រតនា** ភេទប្រុស អាយុ ២៤ឆ្នាំ សញ្ជាតិខ្មែរ មុខរបរសាក់រូប ទីលំនៅកំណើតនៅភូមិ [redacted] ខេត្តព្រៃវែង និងទីកន្លែងបច្ចុប្បន្នស្នាក់នៅបូរីស្ងួនី សង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ **(គេចខ្លួន)**។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **រតនា**។

ជាប់ចោទពីបទ: **ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន** ប្រព្រឹត្តនៅភូមិព្រែកស៊ីង ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ១១ **នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**។



Scanned with CamScanner

-បានឃើញ របាយការណ៍លេខៈ ០៥/២១ របក ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ របស់ស្នងការដ្ឋាននគរបាលខេត្តកណ្តាល នៃអធិការដ្ឋាននគរបាលស្រុកកោះធំ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ១៣២៥ ដក.សព ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ១៤៦៨ ដក.ដស ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ០៩ និង០០នាទីព្រឹក កម្លាំងការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី ផែនការអន្តោប្រវេសន៍ នៃស្នងការដ្ឋាននគរបាលខេត្តកណ្តាល បានសហការជាមួយកម្លាំងនគរបាល នៃអធិការដ្ឋាននគរបាលស្រុកកោះធំ បានធ្វើការស្រាវជ្រាវស៊ើបអង្កេត និងឃាត់ខ្លួនឈ្មោះ [redacted] រតនា,ឈ្មោះ [redacted] ហ៊ាងតឹង និងឈ្មោះ [redacted] វិបុល នៅចំណុចតំបន់សេដ្ឋកិច្ចជីនយ៉ុង ដែលស្ថិតនៅភូមិព្រែកស៊ីង ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ពាក់ព័ន្ធនឹងករណីនាំជនជាតិវៀតណាមឆ្លងដែនចូលមកប្រទេសកម្ពុជាដោយខុសច្បាប់ក្នុងគោលបំណងលក់ដូរមនុស្ស និងកម្លាំងពលកម្ម ដោយនាំចូលពីច្រកព្រំដែនបាវិត មកកាន់រាជធានីភ្នំពេញ។ បច្ចុប្បន្នជនរងគ្រោះឈ្មោះ [redacted] ធិគីមចាង,ឈ្មោះ [redacted] ទុងអ៊ី និងឈ្មោះ [redacted] ស៊ិនង្វៀង កំពុងធ្វើចត្តាឡីស័ក ដោយឡែកនៅយប់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ជនជាប់ឈ្មោះ [redacted] រតនា បានរត់ចេញពីការឃុំឃាំងរបស់សមត្ថកិច្ច។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] **ហ៊ាងតឹង** បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ឈ្មោះ [redacted] រតនា បានទូរស័ព្ទមកខ្លួនឱ្យនាំមនុស្សពីបាវិតមកជ្រៃធំមានមនុស្សចំនួន ០២នាក់ ក្នុងនោះមានប្រុសម្នាក់ និងស្រីម្នាក់ យកតម្លៃ ៧០ដុល្លាអាមេរិក ដោយជិះឡានតាក់ស៊ី។ ក្រោយ ០២ថ្ងៃ សមត្ថកិច្ចឃាត់ខ្លួន និងបានដកហូតម៉ូតូ ០១គ្រឿងម៉ាក ហុងដា។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖ ក្រោយពីបានសួរដេញដោលនាពេលសវនាការ ឃើញថា កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ ប្រព្រឹត្តនៅភូមិព្រែកស៊ីង ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ជនជាប់ចោទឈ្មោះ [redacted] ហ៊ាងតឹង និងឈ្មោះ [redacted] រតនា ពិតជាបានប្រព្រឹត្តបទៈ **ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន** តាមបញ្ញត្តិមាត្រា ១១ នៃ**ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ** ប្រាកដមែន ដូច្នេះតំណាងអយ្យការស្នើសុំតម្កល់បទចោទប្រកាន់ទុកដដែល ជូនតុលាការសម្រេចតាមច្បាប់កំណត់។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហ៊ាងតឹង៖ ខ្លួនសូមលើកអង្គហេតុ និងចម្លើយនៅគ្រប់ដំណាក់កាល ឃើញថា ជនជាប់ចោទពុំបានប្រព្រឹត្តដូចតំណាងអយ្យការចោទប្រកាន់ទេ។ ធាតុផ្សំមាន ៣សំខាន់ៗដែលមិនអាចខ្វះបាននោះគឺ ធាតុផ្សំនីត្យានុកូល ,ធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈ និងធាតុអត្តនោម័ត ឬចេតនាប្រព្រឹត្តបទល្មើស។ ជនជាប់ចោទបានសារភាពថា គាត់បានទទួលប្រាក់ចំនួន ៧០ដុល្លាអាមេរិក ដោយគ្រាន់តែថ្លៃហៅតាក់ស៊ីតែប៉ុណ្ណោះ។ ចម្លើយនៅដំណាក់កាលនគរបាល ពុំបានជួញដូរមនុស្សទេ។ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីក៏មិនបានបង្ហាញថា កូនក្តីរបស់ខ្លួនជួញដូរមនុស្សដែរ។ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ពុំបានទាក់ទងនឹងកូនក្តីរបស់ខ្លួនទេ។ យោងតាមមាត្រា ៤ វាក្យខណ្ឌ នៃក្រមព្រហ្មទណ្ឌ គ្មានចេតនា គឺគ្មានបទល្មើស សំណូមពរឱ្យជនជាប់ចោទរួចផុតពីបទចោទ។

-សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វតនា៖ យោងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វតនា នៅដំណាក់កាលនគរបាលបានឆ្លើយថា ពិតជាបាននាំមនុស្សដោយខុសច្បាប់ប្រាកដមែន សំណូមពរ ជួយបន្ធូរបន្ថយទោស។

+សម្ដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ាងតឹង៖ ស្នើសុំឱ្យខ្លួនរួចផុតពីបទចោទ ដោយសារខ្លួនពុំបានប្រព្រឹត្តទេ។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីកាពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ឯកសារ ភស្តុតាង

-ក្រោយពីបានពិនិត្យ ពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ។

**សំអាងហេតុ**

១.តុលាការទទួលសំណុំរឿងព្រហ្មទណ្ឌពីចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ដែលមានជនជាប់ចោទឈ្មោះ [redacted] **ហ៊ាងតឹង** ភេទប្រុស អាយុ ២៦ឆ្នាំ និងឈ្មោះ [redacted] **វតនា** ភេទប្រុស អាយុ ២៤ឆ្នាំ ពីបទ៖ **ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន** តាមដីកាដំណោះស្រាយ៖ ១៤៦៨ ដក.ដស ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០២១ តុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទយោងតាមមាត្រា ២៨៩ ,មាត្រា ២៨១ និងមាត្រា ៣៤៨ នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ**។

២.ផ្អែកតាមចម្លើយនៅគ្រប់ដំណាក់កាលរបស់ជនជាប់ចោទឈ្មោះ [redacted] **ហ៊ាងតឹង** ព្រមទាំងភស្តុតាង ឃើញថាជនជាប់ចោទពុំបាននាំមនុស្សឆ្លងដែនពីប្រទេសវៀតណាម មកប្រទេសកម្ពុជាទេ តែនៅពេលក្រុមហ៊ុននៅប្រទេសកម្ពុជាបានទាក់ទងមានមនុស្សឆ្លងដែនចូលមក ជនជាប់ចោទរូបនេះគ្រាន់តែជួយរកតាក់ស៊ីទៅទទួលពីព្រំដែនមកភ្នំពេញតែប៉ុណ្ណោះ ដោយយកលេខទូរស័ព្ទអ្នកចូលមកពីក្រុមហ៊ុនផ្ញើទៅឱ្យតាក់ស៊ីជាអ្នកទាក់ទង និងទទួលយកមកតាមច្រកមួយណា គឺអ្នកបើកតាក់ស៊ីជាអ្នកប្រាប់ឱ្យចូលតាមច្រកណាដោយខ្លួនឯង ដោយជនជាប់ចោទរូបនេះទទួលតម្លៃក្នុងមនុស្សម្នាក់ថ្លៃ ២០ ដុល្លាអាមេរិក គិតលុយពីអ្នកបើកតាក់ស៊ី តែចំពោះអ្នកបើកតាក់ស៊ីបានគិតតម្លៃពី ៣៥០ដុល្លាអាមេរិក ដល់ ៤៣០ដុល្លាអាមេរិក ក្នុងមនុស្សម្នាក់ ដោយភាគច្រើនចូលតាមច្រកបាវិត, ភ្នួមសំណ និងជ្រៃធំ។ ជនជាប់ចោទជាអ្នកជួយទទួលដឹកជញ្ជូនដោយមិនស្របច្បាប់ក្នុងគោលដៅជួយដល់ជនល្មើស។ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ាងតឹង មិនមែនជាបទ **ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន** តាមបញ្ញត្តិមាត្រា ១១ នៃ**ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**ទេ តែគឺជាបទ **ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស** ដែលមានចែងតាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្ដី**ពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ** ដូច្នេះគប្បីកែប្រែបទចោទពីបទ **ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន** តាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើ**ជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ** មកជាបទ **ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស** ដែលមានចែងតាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្ដីពីការ បង្ក្រាប**អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**។



Scanned with CamScanner

៣.ផ្អែកតាមចម្លើយនៅគ្រប់ដំណាក់កាលរបស់ជនជាប់ចោទឈ្មោះ [redacted] **រតនា** ព្រមទាំងភស្តុតាង ឃើញថា ជនជាប់ចោទឈ្មោះ [redacted] រតនា ជាអ្នកនាំយកជនដទៃពីប្រទេសវៀតណាមមកប្រទេសកម្ពុជាដោយមិនស្របច្បាប់។ អំពើរបស់ជនជាប់ចោទ គឺជាអង្គហេតុគ្រប់នឹងធាតុផ្សំបទល្មើស **ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន** ដែលមានចែងតាមបញ្ញត្តិមាត្រា ១១ នៃ**ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**។

៤.ជនជាប់ចោទឈ្មោះ [redacted] **ហ៊ាងតឹង** និងឈ្មោះ [redacted] **រតនា** មានសតិសម្បជញ្ញៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវបទព្រហ្មទណ្ឌនូវទង្វើរបស់ខ្លួន។

៥.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] **រតនា** ពីបទ៖ **ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន** ហើយសុំតម្កល់បទចោទប្រកាន់នេះទុកដដែលនោះ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់។ រីឯការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] **ហ៊ាងតឹង** ពីបទ៖ **ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន** គឺមិនត្រឹមត្រូវទេ។

៦.សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] **ហ៊ាងតឹង**៖ ស្នើសុំឲ្យរួចផុតពីបទចោទប្រកាន់នោះគឺមិនត្រឹមត្រូវទេ។

៧.សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] **រតនា**៖ ស្នើសុំឲ្យបន្ធូរបន្ថយទោស តុលាការនឹងពិនិត្យពិចារណា។

៨.មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ហ៊ាងតឹង** ភេទប្រុស អាយុ ២៦ឆ្នាំ ពីបទ៖ **ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស** ប្រព្រឹត្តនៅភូមិព្រែកស៊ីង ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០ នៃ**ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**។

៩.មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **រតនា** ភេទប្រុស អាយុ ២៤ឆ្នាំ ពីបទ៖ **ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន** ប្រព្រឹត្តនៅភូមិព្រែកស៊ីង ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១១ នៃ**ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**។

១០.អំពើជនជាប់ចោទឈ្មោះ [redacted] **ហ៊ាងតឹង** និងឈ្មោះ [redacted] **រតនា** បានប្រព្រឹត្តធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរាបរយសាធារណៈ និងសន្តិសុខសង្គម ដូច្នេះទណ្ឌកម្ម ដែលត្រូវអនុវត្តលើជនជាប់ចោទនីមួយៗ តុលាការនឹងពិចារណា។

១១.វត្ថុចាប់យកតាមកំណត់ហេតុទទួលវត្ថុតាងរបស់អយ្យការ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាលមាន៖ ម៉ូតូ ០១គ្រឿងម៉ាក Honda c125 ពណ៌ស ផ្លាកលេខភ្នំពេញ 1IQ-0781 ជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើស គប្បីរឹបអូស។

**ហេតុដូច្នេះសម្រេច**

១/-កែប្រែបទចោទប្រកាន់លើឈ្មោះ **ង្វៀង ហ៊ាងតឹង** ភេទប្រុស អាយុ ២៦ឆ្នាំ ពីបទ **ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន** តាមបញ្ញត្តិមាត្រា ១១ នៃ**ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើ**



Scanned with CamScanner

**អាជីវកម្មផ្លូវភេទទេ** មកជាបទ **ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស** តាមបញ្ញត្តិមាត្រា ២០ **នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**។

២/-ផ្តន្ទាទោសឈ្មោះ [redacted] ហ៉ងតឹង ភេទប្រុស អាយុ ២៦ឆ្នាំ ដាក់ពន្ធនាគារក្នុងកំណត់រយៈពេល ២(ពីរ)ឆ្នាំ តែទោសនេះអនុវត្តក្នុងពន្ធនាគារ ១៣(ដប់បី)ខែ ទោសនៅសល់ត្រូវព្យួរធម្មតា និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០ (បួនលាន)រៀល ពីបទ៖ **ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស** ប្រព្រឹត្តនៅភូមិព្រែកស៊ីង ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ២០ **នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ** ,មាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

៣/-ផ្តន្ទាទោសឈ្មោះ [redacted]រតនា ភេទប្រុស អាយុ ២៤ឆ្នាំ ដាក់ពន្ធនាគារក្នុងកំណត់រយៈពេល ៧(ប្រាំពីរ)ឆ្នាំ ពីបទ៖ **ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន** ប្រព្រឹត្តនៅភូមិព្រែកស៊ីង ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ១១ **នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**។

៤/-រឹបអូសវត្ថុចាប់យកតាមកំណត់ហេតុទទួលវត្ថុតាងរបស់អយ្យការចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាលមាន៖ ម៉ូតូ ០១គ្រឿងម៉ាក Honda c125 ពណ៌ស ផ្លាកលេខភ្នំពេញ 1IQ-0781។

សាលក្រមនេះជំនុំជម្រះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហ៉ងតឹង , កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] រតនា ,ចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ រក្សាសិទ្ធិប្តឹងទាស់ ឬប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| | **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|---|
| ហត្ថលេខា និងត្រា | [redacted] | | | |

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃច័ន្ទ ១២ កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខេត្តកណ្តាល ,ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២

**បានឃើញ**

**ប្រធានក្រុមប្រឹក្សា**

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner